# ហេតុអ្វីបានជាយើងគួរធ្វើការសន្សំប្រាក់ជាមួយវីសិនហ្វាន់?

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជាបាននឹងកំពុងរីកលូតលាស់ជាលំដាប់ក្នុងរយៈកាលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ក្នុងចំណោមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងនេះវីសិនហ្វាន់ ត្រូវបានគេទទួលស្គាល់ថាជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយដែលលេចធ្លោជាងគេលើសមិទ្ធផលសង្គម។ យោងតាមរបាយការណ៍របស់លោក ឈី ឈិនហូ អគ្គនាយកនៃ វីសិនហ្វាន់ ខេមបូឌា បានឲ្យដឹងថា វីសិនហ្វាន់ ខេមបូឌា គឺជាគ្រឹះស្ថានតែមួយគត់នៅកម្ពុជាដែលមានបណ្តាញអន្តរជាតិកំពុងប្រត្តិបត្តិការក្នុងប្រទេសចំនួន ៣៦ ជុំវិញពិភពលោក។ ដោយមានចក្ខុវិស័យ “ចង់ឃើញកុមារគ្រប់រូបមានជីវិតពេញបរិបូណ៌ សេចក្តីអធិស្ឋានរបស់យើង សូមឲ្យទឹកចិត្តមនុស្សគ្រប់រូបមានឆន្ទៈ ដើម្បីសម្រេចបំណងនេះ” វីសិនហ្វាន់មានគោលបំណងធ្វើឱ្យជីវិតរបស់កុមារប្រសើរឡើង តាមរយៈការផ្តល់ប្រាក់កម្ចីខ្នាតតូច និងសេវាហិរញ្ញវត្ថុដទៃទៀតដល់គ្រួសារដែលត្រូវការសេវាកម្មទាំងអស់នេះ។ សេវាកម្មប្រាក់សន្សំនេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងជួយសម្រួលគ្រួសារដែលមានប្រាក់ចំណូលលើសពីតម្រូវការ ហើយមានឆន្ទៈចង់ជួយជនក្រីក្រតាមរយៈ វីសិនហ្វាន់ ខេមបូឌា និង ជួយសម្រួលដល់គ្រួសារក្រីក្រដាក់ប្រាក់សន្សំ ដើម្បីទុកប្រើប្រាស់ក្នុងករណីមានគ្រោះអាសន្ន ឬហេតុការណ៍កើតឡើងជាយថាហេតុ។**



*Mr. Chee Chin Hoe*

**សមិទ្ធផលសង្គម៖**
អត្តសញ្ញាណសំខាន់នៃវីសិនហ្វាន់គឺសមិទ្ធផលសង្គមដែលមាននៅក្នុងឈាមជ័ររបស់គ្រឹះស្ថាននេះ ដោយសារតែវាជាលំហូរមកពីអង្គការមេ (Parent Organization) របស់វីសិនហ្វាន់ គឺអង្គការទស្សនៈពិភពលោក (ជាអង្គការមនុស្សធម៌អន្តរជាតិ ដែលបង្កើតឡើងយូរមកហើយ)។ វីសិនហ្វាន់បានព្យាយាមយ៉ាងខ្លាំង ដើម្បីបញ្ជៀបសមិទ្ធផលសង្គម ទៅក្នុងផលិតផល និងសេវាកម្មរបស់ពួកគេតាមរយៈជំនឿដ៏មុតមាំរបស់ខ្លួន ក្នុងការដឹកនាំទៅរកសេចក្តីប្រាថ្នាដែលវីសិនហ្វាន់ចង់បាន។

ប្រសិនបើអ្នកប្រៀបធៀបមូលដ្ឋានទាំង៤របស់វីសិនហ្វាន់ទៅនឹងឈើឆ្កាងផ្នែកកំពូលនៃឈើឆ្កាង គឺវីសិនហ្វាន់មានផលិតផលប្រាក់កម្ចីនិងសេវាហិរញ្ញវត្ថុនានាដែលផ្តល់លទ្ធភាពដល់អតិថិជនក្នុងការបង្កើត ឬពង្រីកអាជីវកម្មរបស់ខ្លួន។ ចំណែកផ្នែកខាងក្រោមនៃឈើឆ្កាង វីសិនហ្វាន់ក៏ផ្តល់សំណាញ់ការពារសុវត្ថិភាព ជួយដល់អតិថិជនតាមរយៈផលិតផលប្រាក់សន្សំ និងការទទួលបានការការពារដោយឥតគិតថ្លៃពីវីសិនហ្វាន់ ក្នុងករណីពួកគេជួបហេតុការអកុសល ដែលមិនបានរំពឹងទុក ដោយវីសិនហ្វាន់នឹងលុបចោលបំណុលរបស់អតិថិជន ក្នុងករណីអតិថិជនជួបឧបទ្ទវហេតុដល់ជីវិត។ ក្រឡេកទៅមើលស្លាបម្ខាងនៃឈើឆ្កាងនេះវិញ វីសិនហ្វាន់ផ្តល់ជូនដល់អតិថិជននូវ ការយល់ដឹងកាន់តែប្រសើរឡើង នៃមូលដ្ឋានក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ តាមរយៈកម្មវិធីអប់រំផ្នែកហិរញ្ញវត្ថុផ្តល់ដោយស្ថាប័ន។ រីឯនៅលើស្លាបម្ខាងទៀត វីសិនហ្វាន់ ជួយតភ្ជាប់អតិថិជនរបស់វីសិនហ្វាន់ ទៅនឹងភ្នាក់ងារជាដៃគូជាច្រើន ដែលអាចបំពេញនូវសេវាកម្មបន្ថែម ក៏ដូចជាជំនួយបច្ចេកទេសដែលក្នុងនោះរួមបញ្ចូលទាំងអង្គការទស្សនៈពិភពលោកផងដែរ។

**សមិទ្ធផលផ្នែកហិរញ្ញវត្ថុ៖**
ទន្ទឹមនិងការទទួលបានអត្តសញ្ញាណដ៏ល្អ និងភាពរឹងមាំនៃសមិទ្ធផលសង្គម វីសិនហ្វាន់ ក៏ទទួលបានការកើនឡើងនៃប្រាក់ចំណេញសុទ្ធ ប្រកបដោយនិរន្តភាពពី១,៧៨លានដុល្លារអាមេរិកក្នុងឆ្នាំ២០១១ ទៅ២,៩១លានដុល្លារអាមេរិកក្នុងឆ្នាំ២០១២ ។ លោក ឈី ឈិនហូបានចែករំលែកជាមួយអ្នកយកព័ត៌មានរបស់ទស្សនាវដ្តី ពាណិជ្ជកម្មកម្ពុជា អំពីគន្លឹះសំខាន់ជាច្រើន ដែលនាំឲ្យមានកំណើនប្រាក់ចំណេញដល់វីសិនហ្វាន់ដូចជា៖

**កំណើននៃប្រត្តិបត្តិការប្រកបដោយគុណភាព៖** វីសិនហ្វាន់បានពង្រីកប្រតិបត្តិការពី១៨ខេត្តក្នុងឆ្នាំ២០១១ ទៅចំនួន២០ខេត្តក្រុងនៅឆ្នាំ២០១២ និង២២ខេត្ត ក្រុងក្នុងឆ្នាំ២០១៣។ ចំនួនអតិថិជនសកម្មបានកើនឡើងពី ១៣២.០០០ នៅឆ្នាំ២០១១ ទៅ ១៥៧.០០០ នៅក្នុងឆ្នាំ២០១២ និងជិត១៩០.០០០ នៅឆ្នាំ២០១៣។ ផលប័ត្រឥណទានកើនឡើង២៧,៣ភាគរយ ពី៣៧,៧ លានដុល្លារអាមេរិកក្នុងឆ្នាំ២០១១ ដល់៤៨លានដុល្លារសហរដ្ឋអាមេរិកក្នុងឆ្នាំ២០១២ និងបន្តកើនឡើងរហូតដល់ជាង ៦០លានដុល្លារអាមេរិកគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០១៣នេះ។

**របាយការណ៍តុល្យការដ៏រឹងមាំ៖** ស្របជាមួយនឹងគោលការណ៍នៃវីសិនហ្វាន់ ប្រាក់ចំណេញសុទ្ធទាំងអស់ គឺត្រូវបានរក្សាទុកនៅក្នុងអាជីវកម្ម ដើម្បីបន្តការគាំទ្រដល់អតិថិជន ដោយមិនដែលបានបែងចែកភាគលាភទៅឱ្យម្ចាស់ហ៊ុនណាមួយឡើយ។ ដោយមានមូលដ្ឋានដើមទុនដ៏រឹងមាំ និងប្រភពមូលនិធិចម្រុះ ធ្វើឲ្យចំណាយផ្នែកហិរញ្ញវត្ថុរបស់វីសិនហ្វាន់ មានការថយចុះគួរអោយកត់សំគាល់ពី ៧,៦ភាគរយ ទៅ ៧,១ភាគរយ។

**ផលិតភាពការងាររបស់បុគ្គលិក៖** វីសិនហ្វាន់បានបំពាក់បំប៉នបុគ្គលិកបម្រើការងារ អោយមានចំណេះដឹងនិងជំនាញដ៏ត្រឹមត្រូវ។ ផលិតភាពការងាររបស់បុគ្គលិកកើនឡើង ដោយនៅក្នុងឆ្នាំ២០១១ មន្ត្រីឥណទានម្នាក់ធ្វើការបម្រើអតិថិជនចំនួន៣៨៣នាក់ (ផលប័ត្រឥណទានចំនួន ១០៩.០០០ ដុល្លារអាមេរិច) ចំណែកនៅឆ្នាំ២០១២ មន្ត្រីឥណទានម្នាក់អាចបម្រើអតិថិជនចំនួនដល់ទៅ៣៨៧នាក់ (ផលប័ត្រឥណទានចំនួន១១៩.០០០ដុល្លារអាមេរិច) និងក្នុងឆ្នាំ២០១៣គិតត្រឹមខែវិច្ឆិកានេះ ផលិតភាពការងាររបស់បុគ្គលិកមានកើនឡើងដោយក្នុងមន្ត្រីឥណទានម្នាក់អាចបម្រើអតិថិជនដល់ទៅ៣៩៩នាក់ (ផលប័ត្រឥណទានចំនួន១២៨.០០០ដុល្លារអាមេរិក)។

**ភាពសម្បូរបែបនៃផលិតផល៖** វីសិនហ្វាន់តែងតែយកចិត្តទុកដាក់ទៅលើការផ្តល់យោបល់ពីអតិថិជន និងភាគីពាក់ព័ន្ធ ព្រមទាំងបន្តការអភិវឌ្ឍដំណើរការផលិតផល និងសេវាកម្មអោយកាន់តែប្រសើរឡើងដោយនាំមកនូវផលិតផលកម្ចីសង្គមជាច្រើនប្រភេទដូចជា៖ កម្ចីលើការសិក្សាកម្ចី